ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## លោក ទេព ឧទ្ធី អនុប្រធាននាយកដ្ឋាន និងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយរញ្ជួយចិត្តក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសក **ឋាវ តុងនី** ដែលត្រូវជាឪពុក លោក **ទេព ឧទ្ធី** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និងទំនាក់ទំនងអន្តរជាតិ នៃសាលាភូមិន្ទរដ្ឋបាល បានទទួលមរណភាព នៅថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ២២:០០ នាទីយប់ ក្នុងជន្មាយុ ៧៩ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាអនេកប្បការជាមួយលោក និងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ ឧបាសក **ឋាវ តុងនី** ដែលជាឪពុក និងជីតាជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបបួងសួងជូនវិញ្ញាណក្ខន្ធ ឧបាសក **ឋាវ តុងនី** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោក និងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

ព្រំ-សុខា